# មេរៀនទី ៤៧៖ យ៉ូសែបបានអត់ទោសឱ្យបងប្អូន របស់គាត់

[លោកកុប្បត្តិ ៤២-៤៥]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/rjKrUudfwww

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/m8XIQ8WNBjs

**គោលបំណង៖** ព្រះចង់ឲ្យយើងចេះអត់ទោស

**ខគម្ពីរចងចាំ៖** ម៉ាថាយ ៦៖១២ *"សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. គ្រប់ទាំងអស់ខ្ញុំអាចធ្វើបាន https://youtu.be/YPKAgHMdYog
២. ខ្ញុំអាចធ្វើគ្រប់ការ https://youtu.be/RAti7KCmIvM
៣. ខ្ញុំដឹងខ្លួនហើយ https://youtu.be/cNotISrjHI0

## ១. អធិស្ឋាន

## ២. ចំរៀង
*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ៣. ល្បែងកំសាន្ត




**"ព្រះបានអត់ទោសឲ្យយើងនៅពេលដែល..."**

១. សូមឲ្យកុមារទាំងអស់ក្រោកឈរឡើង។
២. ហើយគាត់អាចអង្គុយចុះនៅពេលដែលគាត់ឆ្លើយនិងសំណួររួច៖ « ព្រះបានអត់ទោសឲ្យយើងរាល់គ្នានៅពេលដែល…» (ចម្លើយអាចជា៖ និយាយកុហក ឈ្លោះ ប្រកែកគ្នា មិនស្តាប់បង្គាប់ឪពុកម្តាយឬនិយាយពាក្យអាក្រក់ជាដើម)
៣. ប្រសិនបើអ្នកត្រូវការសំនួរផ្សេង ទៀតអ្នកអាចសួរកុមារថា "ខ្ញុំបានអត់ ទោសឲ្យអ្នកដទៃនៅពេលពួកគេ…" ។

## ៤.ការណែនាំមេរៀន

រឿងដ៏អស្ចារ្យមួយអំពីព្រះគឺទ្រង់អាចធ្វើឲ្យគ្រប់ការទាំងអស់ឱ្យទៅជាល្អបាន, មិនថាវាជារឿងអាក្រក់ប៉ុណ្ណា

ក៏ដោយ។ ព្រះគម្ពីរបានបង្រៀនយើងជាច្រើនអំពីអ្វីដែលព្រះជាម្ចាស់បានធ្វើ ហើយថាតើព្រះទ្រង់ជា នរ-ណា។ ព្រះគម្ពីរក៏បង្រៀនយើងផងដែរថា យើងគួរតែធ្វើឲ្យដូចជាអ្នកណា? ព្រះជាអ្នកអត់ទោស ចំពោះអំពើបាបរបស់យើង ដោយសារទ្រង់អត់ទោសចំពោះអំពើបាបរបស់យើង យើងគួរតែអត់ទោសឲ្យអ្នកដទៃដែរ។ តើកូនៗឃើញពីទំនាក់ទំនងនេះទេ? នៅពេល ដែលនរណាម្នាក់វាយកូន, វាជារឿងធម្មតាទេដែលយើងចង់វាយគេវិញ។ រឺក៏នៅពេលដែលនរណាម្នាក់និយាយអាក្រក់ដាក់យើង យើងក៏និយាយ ពាក្យអាក្រក់ទៅគេវិញ។ ប៉ុន្តែព្រះគម្ពីរនៅថ្ងៃនេះបានបង្រៀនពួកយើងថា គួរតែចេះអត់ទោស។ យើងអត់ទោសឲ្យគេ ព្រោះយើងដឹងថាព្រះក៏បានអត់ទោសឱ្យយើងដែរ។ នៅពេលយើងចេះអភ័យទោស ដូចជាព្រះ យើងកំពុងតែធ្វើឲ្យព្រះដឹងថាយើងអរព្រះគុណចំពោះការអត់ទោស របស់ទ្រង់ហើយយើងទុកចិត្តទ្រង់។ តាមពិតទៅការអភ័យទោសគឺជាវិធីមួយដែលព្រះនាំការល្អកើតចេញ ពីការអាក្រក់។ ចូរយើងស្វែងយល់ពីរបៀបដែលយ៉ូសែបអាចនាំយកការល្អចេញពីស្ថានភាពដ៏អាក្រក់បាន!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

យ៉ូសែបមានបងប្រុស១០នាក់និងប្អូនប្រុសម្នាក់។ បងប្រុសទាំង១០របស់យ៉ូសែបបានច្រណែនហើយស្អប់គាត់។ នៅពេលពួកគេមានឱកាសពួកគេបានលក់គាត់ធ្វើជាទាសករ។ យ៉ូសែបត្រូវបានបញ្ជូនឲ្យធ្វើជាទាសករនៅអេហ្ស៊ីបហើយគាត់ក្លាយជាទាសករអស់រយៈពេល១៣ឆ្នាំ។ បន្ទាប់មកស្តេចបានសុំឲ្យ គាត់កាត់សុបិន្តមួយសម្រាប់គាត់។ យ៉ូសែបបានធ្វើការយ៉ាងល្អក្នុងការបកស្រាយសុបិននេះ។ គាត់បានប្រាប់ស្តេចថានឹងមាន ៧ឆ្នាំនៃភាពបរិបូរណ៌ និង៧ឆ្នាំនៃភាពអត់ឃ្លាន។ ស្តេចបានផ្តល់ឲ្យយ៉ូសែបនូវឋានៈខ្ពស់បំផុតលំដាប់ទីពីរនៅក្នុងប្រទេសអេហ្ស៊ីប ហើយបានប្រាប់យ៉ូសែបឲ្យជួយប្រជាជន អេហ្ស៊ីបក្នុងការសន្សំ-សំចៃស្បៀងអាហារដើម្បីកុំឲ្យពួកគេអត់ឃ្លានក្នុងពេលទុរ្ភិក្ស(គ្រោះធម្មជាតិ)មកដល់ព្រោះដំណាំរបស់ពួកគេមិនទទួលបានទិន្នផល។

បងប្អូនរបស់យ៉ូសែបរស់នៅស្រុកកាណាន ដែលនៅក្បែរស្រុកអេហ្ស៊ីបហើយ ពួកគេឃ្លានព្រោះគ្មានម្ហូបអាហារទេនៅស្រុកកាណាន។ដូច្នេះពួកគេបាន ធ្វើដំណើរទៅប្រទេសអេហ្ស៊ីប ដើម្បីទិញម្ហូប។ ពួកគេត្រូវទិញអាហារពីយ៉ូសែបតែពួកគេមិនស្គាល់គាត់ទេ។ យ៉ូសែបបានក្លាយជាបុរសដ៏ មានអំណាចម្នាក់ នៅក្នុងប្រទេសអេហ្ស៊ីប។ ទោះបីជាមានរឿងអ្វីក៏យ៉ូ សែបនៅតែស្គាល់បងប្អូនរបស់គាត់ ដែរ។ គាត់បានធ្វើការសាកល្បងជាច្រើនដល់ពួកគេ ដើម្បីដឹងថាតើពួកគេនៅតែអាក្រក់ ឬយ៉ាងណា។ នៅ ពេលដែលយ៉ូសែបបានឃើញថាបងប្អូនរបស់គាត់បានផ្លាស់ ប្តូគាត់បាននិយាយ ថា "ខ្ញុំជាយ៉ូសែបប្អូន ប្រុសរបស់បងៗ។ ខ្ញុំគឺជាអ្នកដែលបងៗបានលក់ជាទាសករ។ បងៗចង់ធ្វើបាបខ្ញុំ ប៉ុន្តែព្រះបានបង្កើតរឿងល្អចេញពីរឿងនេះ!ខ្ញុំអត់ទោសឱ្យបងៗបាន" ។ យ៉ូសែបបានអញ្ជើញបងៗនិងឪពុករបស់គាត់ឲ្យផ្លាស់ទៅអេហ្ស៊ីបដែលជាកន្លែងមានអាហារច្រើន។ យ៉ូសែបបានចិញ្ចឹមថែរក្សាពួកគេគ្រប់គ្នា។

យ៉ូសែបអាច ចាប់បងប្អូនរបស់គាត់ដាក់គុកបានពីបទលក់ គាត់ជាទាសករឬដោយសារ ធ្វើអាក្រក់

ចំពោះគាត់។ ប៉ុន្តែ យ៉ូសែបបានអភ័យទោសឱ្យបងប្អូនរបស់គាត់ ដោយសារគាត់ស្រឡាញ់ និងទុកចិត្តព្រះ។

## ៦. សំនួរពិភាក្សា

១.ហេតុអ្វីបានជាបងប្អូនរបស់យ៉ូសែបស្អប់គាត់?( *ដោយសារពួកគាត់ច្រណែន*)
២.តើយ៉ូសែបបានធ្វើជាទាសករនៅឯប្រទេសណា?( *អេហ្ស៊ីប*)
៣.ហេតុអ្វីបងប្អូនរបស់យ៉ូសែបធ្វើដំណើរទៅប្រទេសអេហ្ស៊ីប?( *ដើម្បីទិញម្ហូបអាហារ*)
៤.ហេតុអ្វីបានជាយ៉ូសែបអភ័យទោសឲ្យបងប្អូនរបស់គាត់?( *ព្រោះគាត់ស្រឡាញ់ និងទុកចិត្តព្រះ ព្រោះវាជាបញ្ជារបស់ព្រះ*)
៥.បើមានគេធ្វើបាបប្អូនៗតើប្អូនឆ្លើយតបទៅគេវិញយ៉ាងដូចម្តេច?( *ឱ្យកុមារឆ្លើយ*)

## ៧. ល្បែងកំសាន្ត “រង្វង់នៃការអភ័យទោស”




១. គូសរង្វង់ធំមួយនៅលើដី
២. យើងទាំងអស់គ្នាបានធ្វើការអាក្រក់មួយ ហើយយើងមានការសោកស្តាយសំរាប់ការនោះ។ នៅពេលយើង ធ្វើការអាក្រក់ យើងនៅក្រៅរង្វង់នៃការអភ័យទោស។ ប៉ុន្តែព្រះបានមានបន្ទូលថា ប្រសិនបើយើងប្រាប់ ទ្រង់ ពីអ្វីដែលយើងបានធ្វើនោះ ទ្រង់នឹងអត់ទោសឱ្យយើង។ ហើយព្រះក៏ប្រាប់យើងថាយើងអាចអភ័យទោសឱ្យគ្នាទៅវិញទៅមកបាន។
៣. គ្រូឈរនៅកណ្តាលរង្វង់ នៅពេលកុមារលឺចម្រៀងសូមឈរនៅឱ្យស្ងៀម។ នៅពេលភ្លេងឈប់ កុមារ ឈានពីរជំហានហើយមានតែពីរជំហានប៉ុណ្ណោះឆ្ពោះទៅរករង្វង់នៃការអភ័យទោស។
៤. នៅពេលពួកគេដើរ ចូលកៀកក្បែររង្វង់ដែលគ្រូអាចប៉ះដៃកុមារបាន ហើយគ្រូនិយាយថា “អ្នកត្រូវបាន អត់ទោសឱ្យហើយ” កុមារអាច ចូលទៅក្នុងរង្វង់ជាមួយគ្រូបាន។
៥. បន្ទាប់មកឲ្យកុមារដែលនៅក្នុងរង្វង់អាចប៉ះដៃកុមារផ្សេង ទៀត ដែរនៅខាងក្រៅរង្វង់ ដោយនិយាយថា “អ្នកត្រូវបានអត់ទោសឲ្យហើយ” ដល់អ្នកផ្សេងផងដែរ។ ធ្វើបែបនេះរហូតដល់សិស្សគ្រប់គ្នាបានចូល មកនៅក្នុងរង្វង់។

## ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ៦:១២** *“សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ”*។

## ៩. ហត្ថកម្ម

ធ្វើហត្ថកម្មដែលអ្នកបានឃើញ ហើយឱ្យកុមារសរសេរខគម្ពីរចងចាំនៅចំកណ្តាល






## ១០. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ: (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ក្នុងនាមជាគ្រីស្ទបរិស័ទយើងមានអំណរជាមួយការការពារ និងការសន្យានៃសេចក្តីស្រឡាញ់របស់ព្រះ ដូច្នេះវាជារឿងចាំបាច់ និងវាជាធម្មជាតិដែលយើងត្រូវអភ័យទោសដល់អ្នកដែលធ្វើឱ្យយើងខកចិត្តឬធ្វើឱ្យយើងឈឺចាប់។ ក្នុងនាមជាអ្នកបម្រើនៅក្នុងនគររបស់ព្រះ វាសំខាន់ណាស់ដែលយើងចេះអភ័យទោសដល់អ្នកដែលធ្វើខុសចំពោះយើង។ តើអ្នកកំពុងរងទុក្ខដោយសារតែនរណាម្នាក់ធ្វើឱ្យអ្នកឈឺចាប់ ឬក៏អ្នកពិបាកនឹងអភ័យទោសឱ្យនរណាម្នាក់ឬ? សូមពិចារណាអំពីការសាកល្បងដែលយ៉ូសែបបានស៊ូទ្រាំ។ អានរឿងរបស់យ៉ូសែបឡើងវិញហើយសុំឱ្យព្រះប្រទានកម្លាំង និងប្រាជ្ញាដល់អ្នកដូចគ្នានឹងអ្វីដែលព្រះបានផ្តល់ឱ្យយ៉ូសែបដើម្បីអភ័យទោសដល់បងប្អូនរបស់គាត់ដែរ។